# ការអនុវត្តន៍ល្អ

## ការងារសំអាតស្នាមប្រឡាក់

រោងចក្រ
កាន់តែប្រសើរ
នៅកម្ពុជា

ដោយសារតែសារធាតុគីមីប្រើសំរាប់សំអាតស្នាមប្រឡាក់អាចបង្ករអោយមានគ្រោះថ្នាក់បាន  ដូចនេះការងារសំអាតស្នាមប្រឡាក់ត្រូវតែដាក់អោយនៅដាច់ដោយឡែកពីកន្លែងផលិតកម្មសំខាន់ៗ។ សំភារៈ និងសំលៀកបំពាក់សុវត្ថិភាព  ត្រូវផ្តល់អោយកម្មករដែលប្រើប្រាស់សារធាតុគីមីសំអាតស្នាមប្រឡាក់។ រោងចក្រដែលមានការរៀបចំការងារសំអាតស្នាមប្រឡាក់បានល្អ  អាចសន្សំថវិកាតាមរយៈការកាត់បន្ថយចំនួនអវត្តមានរបស់កម្មករ  ព្រមទាំងមានការលើកកំពស់សុខភាព និងទឹកចិត្តរបស់កម្មករផង  ។ រោងចក្រដែលមានសុវត្ថិភាពការងារ ក៏អាចជួយបង្កើនការលក់ផងដែរ ដោយសារល័ក្ខខ័ណ្ឌការងារ គឺជាចំណុចសំខាន់ដែលអ្នកបញ្ជាទិញសំលៀកបំពាក់ត្រូវការ ។

### *ការអនុវត្តន៏ល្អសំរាប់ការងារសំអាតស្នាមប្រឡាក់*

បំបែកការងារសំអាតស្នាមប្រឡាក់ចេញពីកន្លែងផលិតកម្ម ដោយដាក់វាឱ្យនៅក្នុងបន្ទប់ដាច់ដោយឡែកមួយ (រូបភាពទី១) ។

ធានាថាបន្ទប់សំអាតស្នាមប្រឡាក់ មានខ្យល់អាកាសល្អគ្រប់ពេលទាំងអស់ តាមរយៈការបំពាក់កង្ហារ និងប្រព័ន្ធបឺតខ្យល់កខ្វក់ចេញពីបន្ទប់ (រូបភាពទី២) ។

កង្ហារនៅក្នុងបន្ទប់សំអាតស្នាមប្រឡាក់ មិនគួរបក់ចំដាក់កម្មករនោះទេ ព្រោះវាអាចធ្វើអោយកម្មករដកដង្ហើមស្រូបចូលនូវសារធាតុគីមី (រូបភាពទី២) ។

ត្រូវផ្តល់អោយកម្មករសំអាតស្នាមប្រឡាក់នូវសំភារៈការពារខ្លួន (PPE) ដូចជា ស្រោមដៃ វ៉ែនតាសុវត្ថិភាព ម៉ាស់ការពារ និងអាវអៀម ។

រោងចក្រជាច្រើនប្រើប្រាស់សារធាតុសំអាតស្នាមប្រឡាក់ ដែលមានជាតិ *ទ្រីក្លូរ៉អេទីឡែន* ។ *ទ្រីក្លូរ៉អេទីឡែន* គឺជាសារធាតុពុល ហើយអាចបង្ករអោយមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ។ ចំនុចសំខាន់ ត្រូវអោយកម្មករពាក់សំភារៈការពារខ្លួន (PPE) ដើម្បីការពារពួកគេកុំអោយប៉ះពាល់ ឬស្រូបសារធាតុគីមីនេះតាមការដកដង្ហើម (រូបភាពទី២ និងទី៣) ។

ធានាថាកម្មករត្រូវបានអប់រំពីរបៀបប្រើប្រាស់សារធាតុគីមីយ៉ាងត្រឹមត្រូវ ។ សន្លឹកទិន្នន័យពត៌មានស្តីពីសុវត្ថិភាពគីមី (MSDSs) ត្រូវតែបានផ្តល់អោយជាភាសាខ្មែរ ។

ធានាថាកម្មករ និងបុគ្គលិកពេទ្យ ដឹងពីអ្វីដែលត្រូវធ្វើក្នុងករណីដែលមានសារធាតុគីមីដែលគ្រោះថ្នាក់បានកំពប់ ឬពេលដែលកម្មករណាម្នាក់រងរបួស ។

ធានាថាកម្មករយល់ដឹងពីរបៀបទុកដាក់សារធាតុគីមីបានយ៉ាងត្រឹមត្រូវ ។



រូបភាពទី១



រូបភាពទី២



រូបភាពទី៣

### អត្ថប្រយោជន៏:

- ✓ បរិយាកាសការងារកាន់តែមានសុវត្ថិភាព
- ✓ កម្មករកាន់តែមានសុខភាពប្រសើរជាងមុន
- ✓ កម្មករកាន់តែសប្បាយចិត្តនៅពេលដែលពួកគេឈប់ទទួលក្លិនមិនល្អ មិនឈឺក្បាល ឬមិនរមាស់ភ្នែកនិងស្បែកយូរទៅទៀត
- ✓ កាត់បន្ថយហានិភ័យសុខភាពនៃការប៉ះពាល់សារធាតុគីមីរយៈពេលវែង
- ✓ កាត់បន្ថយអវត្តមាន ដោយសារតែល័ក្ខខ័ណ្ឌវេជ្ជសាស្ត្រ
- ✓ លើកកំពស់ផលិតភាព

### តាមរបៀបណា:

- ✓ កំណត់កន្លែងសមរម្យមួយ សំរាប់បន្ទប់សំអាតស្នាមប្រឡាក់
- ✓ ទិញសំភារៈការពារខ្លួន (PPE) ដែលចាំបាច់
- ✓ បុគ្គលិករោងជាងរបស់រោងចក្រ ត្រូវរៀបចំដំឡើងបន្ទប់សំអាតស្នាមប្រឡាក់អោយរួចជាស្រេច

### តំលៃ:

**$** ________

- **$** តំលៃទាប
- **$$** តំលៃមធ្យម
- **$$$** តំលៃខ្ពស់